លេខ ១៧៣ ថ្ងៃច័ន្ទ ទី១៩ ខែកញ្ញា ឆ្នាំ២០០៥

ពត៌មានក្នុងប្រទេស

# ព្រះមហាក្សត្រយាងជាព្រះអធិបតីក្នុងព្រះរាជពិធីបុណ្យសង្ឃទាន ថ្វាយព្រះកុសលចំពោះវិញ្ញាណក្ខន្ធ សម្តេច នរិន្ទ្រៈពង្ស

*លោក ចង លីមអ៊ី AKP ភ្នំពេញ*

នៅព្រះបរមរាជវាំង កាលពីព្រឹកថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៥ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គបានសព្វព្រះរាជហឫទ័យ ស្តេចយាងជាព្រះអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងព្រះរាជពិធីបុណ្យសង្ឃទាន ថ្វាយព្រះកុសលចំពោះព្រះវិញ្ញាណក្ខន្ធសម្តេច នរោត្តម នរិន្ទ្រៈពង្ស ដែលត្រូវជាព្រះរាជអានុចបង្កើតរបស់ព្រះអង្គ ។

នៅក្នុងព្រះរាជពិធីបុណ្យ ដែលបានប្រព្រឹត្តទៅយ៉ាងឱឡារិក តាមគន្លងព្រះពុទ្ធសាសនានាឱកាសនោះ ព្រះករុណា ព្រះមហាក្សត្រ បានថ្វាយគ្រឿងសក្ការៈបូជាចំពោះព្រះរតនត្រៃយ៍ នៅព្រះវិហារព្រះកែវមរកត និងតាមទីសក្ការៈនានាក្នុងព្រះបរមរាជវាំង ព្រមទាំងនៅព្រះចេតីយ៍តំកល់ព្រះអដ្ឋិធាតុ សម្តេចនរិន្ទ្រៈពង្ស ដើម្បីជាការសំដែងនូវព្រះរាជគារវកិច្ចគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះរាជគុណូបការៈដ៏ថ្លៃថ្លាបំផុតរបស់អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរ ដែលបានដឹកនាំកសាងការពារទឹកដីដ៏បវរនៃយើងឱ្យមានការរីកចំរើនគង់វង្សរហូតដល់សព្វថ្ងៃនេះ ។

បន្ទាប់ពីព្រះរាជពិធីនេះបានបញ្ចប់ ព្រះករុណា ព្រះមហាក្សត្រ បានសព្វព្រះរាជហឫទ័យប្រារព្ធឡើងនូវព្រះរាជពិធីបុណ្យដ៏ឧត្តុង្គឧត្តមមួយទៀត គឺការឧទ្ទិសព្រះរាជទ្រព្យដ៏ថ្លៃថ្លារបស់ព្រះអង្គ មានជាសម្ភារៈ បរិក្ខារ និងបច្ច័យ ដើម្បីប្រគេនព្រះសង្ឃចំនួន ១២វត្ត នៅក្នុងខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តកំពង់ធំ ដែលមួយខេត្ត១មាន ៤វត្ត ។ សម្ភារៈបរិក្ខារ និងចតុបច្ច័យដែលវត្តនីមួយៗទទួលបាន រួមមានអង្ករ ៥០គីឡូក្រាម (២បាវ) អំបិលសុខភាពចំនួន ៥គីឡូក្រាម ត្រីខចំនួន ២០កំប៉ុង មីចំនួន ២កេះ ក្នុង១កេះ មាន ៣០កញ្ចប់ ទឹកបរិសុទ្ធចំនួន ២កេះ ទឹកក្រូចចំនួន ២កេះ ទឹកដោះគោ ២៤កំប៉ុងតែ ៥កញ្ចប់ ស្ករសចំនួន ៥ប្រអប់ ទៀនក្រមួនចំនួន ៥ដើម ធូបក្រអូបចំនួន ៥ប្រអប់ និងទេយ្យទានចំនួន ៥កញ្ចប់ ព្រមទាំងបច្ច័យចំនួន ១លានរៀល ដើម្បីរួមចំណែកក្នុងការទ្រទ្រង់ជីវភាពព្រះសង្ឃក្នុងព្រះវស្សារដូវបុណ្យកាន់បិណ្ឌនេះ ។

គួររំលឹកផងដែរថាក្នុងសប្តាហ៍កន្លងទៅនេះ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី បានសព្វព្រះរាជហឫទ័យប្រោសព្រះរាជានុញ្ញាតឱ្យសម្តេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋ

មន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នាំយកព្រះរាជទ្រព្យរបស់ព្រះអង្គចំនួន ៥.០០០ដុល្លារអាមេរិក ថ្វាយព្រះសុគន្ធាធិបតី ប៊ូ គ្រី សម្ដេចសង្ឃរាជគណធម្មយុត្តិកនិកាយ ដែលជាព្រះរាជទ្រព្យដ៏ឧត្ដុង្គឧត្ដម សំរាប់ចូលរួមកសាងពុទ្ធិកមហាវិទ្យាល័យ ព្រះសីហមុនីរាជ ស្ថិតនៅក្នុងវត្តស្វាយពពែ រាជធានីភ្នំពេញ និងព្រះរាជទ្រព្យចំនួន ១.០០០ដុល្លារអាមេរិកទៀតទៅប្រគេនគណៈកម្មាធិការអាចារ្យវត្តពោធិ៍ព្រះថ្កល់ស្ថិត នៅក្នុងភូមិក្បាលពោធិ៍ ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ ដើម្បីចូលរួមកុសលកសាងបង្ហើយឧបត្ថម្ភសាលា ក្នុងទីអារាមវត្តពោធិ៍ព្រះថ្កល់ ។/

## <u>សម្ដេច ហ៊ុន សែន</u> : "ការអភិវឌ្ឍន៍ត្រូវតែស្ថិតនៅជាបេះដូង នៃការយកចិត្តទុកដាក់របស់សហគមន៍អន្តរជាតិ"

*លោក ជឹម ណារី AKP ភ្នំពេញ*

នៅក្នុងសុន្ទរកថាថ្លែងទៅកាន់សម័យប្រជុំពេញអង្គនៃមហាសន្និបាតលើកទី៦០ របស់អង្គការសហប្រជាជាតិ (អ.ស.ប) កាលពីថ្ងៃទី១៥ កញ្ញា ឆ្នាំ២០០៥ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ហើយ ដែលត្រូវបានចាក់ផ្សាយបន្តផ្ទាល់ដោយទូរទស្សន៍ CTN នោះ សម្ដេច ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាល កម្ពុជា បានគូសបញ្ជាក់ថា ការអភិវឌ្ឍន៍ត្រូវតែស្ថិតនៅជាបេះដូង នៃការយកចិត្តទុកដាក់របស់សហគមន៍ អន្តរជាតិ ឆន្ទៈនយោបាយពិតប្រាកដ គឺជាបុរេល័ក្ខខ័ណ្ឌដ៏សំខាន់បំផុត ដើម្បីឈានទៅសំរេចបាននូវ គោលដៅអភិវឌ្ឍន៍សហស្សវត្ស ។

សម្ដេចនាយករដ្ឋមន្ត្រី បានរំលឹកឡើងនូវចំណុចមួយចំនួន ពាក់ព័ន្ធនឹងដំណើរទៅមុខនៃពិភព លោកដ៏ផុយស្រួយរបស់យើងក្នុងសតវត្សទី ២១ នេះ ។

*សេរីភាពចាកផុតពីសេចក្ដីស្រេកឃ្លាន* : យើងខ្ញុំឯកភាពទាំងស្រុងចំពោះកាលវិភាគរបស់ ឯ.ឧ អគ្គលេខាធិការ អ.ស.ប លើបញ្ហាអន្តរសកម្មរវាងសិទ្ធិមនុស្ស នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ សន្តិសុខ និងការអភិវឌ្ឍន៍ ដូច្នេះយើងត្រូវធ្វើការងារលើសមរភូមិទាំងអស់នេះ ក្នុងពេលតែមួយលុះត្រាតែបុព្វហេតុ អន្តរសកម្មទាំងអស់នេះដើរទៅមុខព្រមៗគ្នា ទើបយើងអាចសំរេចបានជោគជ័យ ។ ភាពជាដៃគូជាសកល រវាងប្រទេសអ្នកមាន និងប្រទេសអ្នកក្រ ត្រូវតែផ្អែកទៅលើការគោរពគ្នា និងការទុកចិត្តគ្នាទៅវិញទៅមក ការចែករំលែក ការទទួលខុសត្រូវ និងតម្លាភាព ។ ប្រជាជាតិ និងស្ថាប័នអ្នកផ្ដល់ជំនួយគួរតែបោះជំហាន ឱ្យបានឆាប់រហ័សក្នុងការប្រែក្លាយវោហាសាសន៍នៃសេចក្ដីថ្លែងការណ៍ទីក្រុងរ៉ូម និងទីក្រុងប៉ារីស ឱ្យទៅជា ការពិតជាក់ស្ដែងដែលផ្ដល់ការគាំទ្រហ្មត់ចត់ និងឥតងាករេចំពោះភាពជាម្ចាស់ដ៏ពេញលេញរបស់ប្រជាជាតិ ដែលទទួលជំនួយទាំងផ្នែកដំណើរការ ទាំងក្នុងការកំណត់អាទិភាព នៃការអភិវឌ្ឍន៍ ។ សម្ដេចបានគូស បញ្ជាក់ថា: គេត្រូវបញ្ចប់របៀបវារៈដែលបង្កប់នូវគោលដៅនយោបាយ និងមនោគមវិជ្ជា ដើម្បីសង្កត់លើ

ប្រទេសទទួលជំនួយ ទង្វើបែបនេះបានត្រឹមតែដាក់ទណ្ឌកម្មលើអ្នកក្រីក្រតែប៉ុណ្ណោះ ។ ជាក់ស្តែងជាមួយនឹងនិន្នាការធ្លាក់ចុះនៃជំនួយ គេក៏សង្កេតឃើញហាក់ដូចជាមានការកើនឡើងផងដែរនូវចំណងនិងលក្ខ័ណ្ឌនានាដែលផ្សាភ្ជាប់ទៅនឹងជំនួយ ។ ជំនួយភាគច្រើន ហាក់ដូចជាមិនសូវបានធ្លាក់ទៅដល់ជនក្រីក្រពិតប្រាកដនោះទេ ដោយសារតែការចាយវាយយ៉ាងសន្ធឹកសន្ធាប់ទៅលើជំនួយបច្ចេកទេស និងការសិក្សាផ្សេងៗ ព្រមទាំងវិស័យមួយចំនួនទៀត ដែលមិនត្រូវនឹងអាទិភាពនៃការអភិវឌ្ឍន៍របស់ប្រទេសដែលទទួលជំនួយ តែស្របតាមការចង់បានរបស់ម្ចាស់ជំនួយ ហើយចុងក្រោយបំផុត ថវិកាភាគច្រើនក៏ត្រូវតែត្រឡប់ទៅបំរើអោយសេដ្ឋកិច្ចរបស់ប្រទេសម្ចាស់ជំនួយវិញ ឬក៏ត្រូវបានទៅបំរើឱ្យពួកស្វែងរកការងារធ្វើមកពីប្រទេសផ្សេងៗ ទោះបីអ្នកនោះខ្វះសមត្ថភាព និងមិនស្គាល់ប្រទេសទទួលជំនួយយ៉ាងណាក៏ដោយ ។ ទន្ទឹមនិងនេះ ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវតែខិតខំប្រឹងប្រែងក្នុងការកែទម្រង់ផងដែរ ពិសេសគឺការគៀងគរចំណូលក្នុងស្រុក ការពង្រឹងអភិបាលកិច្ច និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ យើងខ្ញុំសូមស្វាគមន៍ដល់ការសំរេចចិត្តរបស់បណ្តាប្រទេសជឿនលឿនទាំង ៨ ដែលបានលុបចោលនូវបំណុលនៃប្រទេសក្រីក្រចំនួន១៨ ដែលមានទឹកប្រាក់ប្រមាណ ៤០ពាន់លានដុល្លារ ក៏ប៉ុន្តែនេះគ្រាន់តែជាការជួយសង្គ្រោះ មិនមែនជាដំណោះស្រាយបញ្ហានោះទេ ។ ការអភិវឌ្ឍន៍ប្រកបដោយជោគជ័យ តំរូវឱ្យមានការផ្ទេរធនធានសុទ្ធកាន់តែច្រើនឡើង សំរាប់ការវិនិយោគពិតប្រាកដនៅក្នុងប្រទេសក្រីក្រ ពិសេសតាមរយៈការផ្តល់ជំនួយឥតសំណងដែលកំពុងតែមាននិន្នាការស្រុតចុះពីមួយឆ្នាំទៅមួយឆ្នាំ ។ ម្យ៉ាងទៀតគេគួរតែទន់ភ្លន់ក្នុងការអនុញ្ញាតឱ្យប្រទេសក្រីក្រ អាចប្រើប្រាស់កម្ចីសំរាប់អភិវឌ្ឍន៍គំរោងមួយចំនួនដែលផ្តល់ផលប្រយោជន៍ដ៏ធំធេងដល់សេដ្ឋកិច្ចជាតិ មានអត្រាចំណូលផ្ទៃក្នុងខ្ពស់ ធានាបានចំណូលជារូបិយប័ណ្ណ ហើយមិនធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពសងបំណុល និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសសាមី ។ យើងត្រូវបង្វែសកម្មភាពរបស់យើងចេញ ពីការផលិតរបាយការណ៍ក្រដាសដ៏ច្រើនលើសលុប ហើយផ្តោតការយកចិត្តទុកដាក់លើការផ្តល់ជំនួយសង្គ្រោះ ឬជំនួយអភិវឌ្ឍន៍ដល់អ្នកក្រវិញ ។ សមានចិត្តដ៏ឧត្តុង្គឧត្តមនៃកុងសង់ស៊ីសនៃទីក្រុងម៉ុងត្រេក្នុងការតម្លើងជំនួយអភិវឌ្ឍន៍ឱ្យដល់ ០,៧ភាគរយ នៃ ផ.ស.ស ត្រូវតែប្រែក្លាយទៅជាការពិភាក្សាក្នុងការអនុវត្តន៍ជាក់ស្តែង ។ គេត្រូវធ្វើឱ្យទៅជាតថភាពពិតប្រាកដនូវប្រព័ន្ធពាណិជ្ជកម្មដោយយុត្តិធម៌រវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ដើម្បីឱ្យប្រទេសក្រីក្រអាចប្រើប្រាស់សក្តានុពលរបស់ខ្លួនបានពេញលេញ ហើយជួយធ្វើអតិបរមាកម្មឧត្តមភាពប្រៀបធៀបសំរាប់កំណើនរបស់ពួកគេ ។ យើងខ្ញុំសូមគាំទ្រដល់គោលដៅរបស់សន្និសីទអន្តរជាតិស្តីពីប្រជាជន និងការអភិវឌ្ឍន៍ដើម្បីឱ្យសំរេចបានជាសកលនូវសេវាសុខភាពបន្តពូជមុនឆ្នាំ ២០១៥ នៅក្នុងបរិវេណនៃការធានាអភិបាលកិច្ចរឹងមាំខាងផ្នែកបរិស្ថានកម្ពុជាសូមស្វាគមន៍ ចំពោះការផ្តល់សច្ចាប័នលើពិធីសារទីក្រុងតូក្យូ ក្នុងគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នពុល ។

*សេរីភាពរួចចាកផុតពីការភ័យខ្លាច:* អំពើភេរវកម្មបង្កឱ្យមានការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ការរីកចំរើន វាមិនត្រឹមតែបំផ្លាញនូវផលចំណេញហើយបង្វិលនូវទិសដៅប្រវត្តិសាស្ត្រឱ្យវិលត្រឡប់ថយក្រោយប៉ុណ្ណោះទេ វាថែមទាំងបង្វែរធនធានដោយកម្រទាំងឡាយរបស់យើងមកប្រឆាំងនឹងភេរវកម្មដោយឆក់យកពីប្រភពធនធានវិនិយោគសំរាប់បំរើឱ្យការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះហើយ នៅពេលដែលយើងទាំងអស់គ្នាកំពុងតែប្រកាន់ខ្ជាប់ នូវគោលជំហរដ៏រឹងមាំក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ភេរវកម្ម យើងគួរតែស្វែងយល់ឱ្យច្បាស់អំពីឫសគល់របស់វា ហើយខិតខំលុបបំបាត់នូវស្ថានភាពទាំងឡាយណាដែលពួកភេរវករអាចទាញផលចំណេញបាន ។ យើងត្រូវខិតខំលុបបំបាត់នូវការអាក់អន់ស្រពន់ចិត្តរបស់អ្នកក្រីក្រ និងអ្នកដែលត្រូវគេបោះបង់ចោល ហើយប្រឹងប្រែងផ្តល់ភាពថ្លៃថ្នូរជូនដល់ពួកគេ ។ ទន្ទឹមនឹងនេះយើងត្រូវតែធានាឱ្យមានការសន្ទនា និងកិច្ចសហប្រតិបត្តិការរវាងអរិយធម៌ វប្បធម៌ និងសាសនាទាំងអស់ គោលដៅចំបង គឺការរស់នៅប្រកបដោយតុល្យភាព ចេះយោគយល់គ្នា ចេះសំរបសំរួល និងការរស់នៅប្រកបដោយសុខដុមជាមួយខ្លួនឯង ជាមួយអ្នកជិតខាង ជាមួយសត្វមានជីវិតឯទៀត ជាមួយធម្មជាតិ និងជាមួយចក្រវាឡ ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានគូសបញ្ជាក់ទៀតថា បញ្ហាប្រឈមនៃយុគសម័យរបស់យើងទាមទារនូវសកម្មភាពនយោបាយដែលកើតចេញដោយផ្ទាល់ពីបញ្ញាញាណ ភាពអង់អាចក្លាហាន និងបេះដូងដ៏បរិសុទ្ធ ។ ការកាត់បន្ថយ និងឈានទៅលុបបំបាត់ភាពក្រីក្រ គឺជាការទទួលខុសត្រូវរួមគ្នារបស់ពិភពលោកទាំងមូល ។ កម្ពុជាត្រៀមខ្លួនជាស្រេចដើម្បីចូលរួមកិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍន៍ សន្តិសុខ និងស្ថេរភាព ។/

## រាជរដ្ឋាភិបាលសំរេចលើសំណើគោលការណ៍ថ្លៃលក់អគ្គីសនីជាថ្មី

*លោក ពេជ្រ ណារិទ្ធ AKP ភ្នំពេញ*

ដោយនិន្នាការតំលៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ ក៏ដូចក្នុងស្រុក មានការកើនឡើងខុសពីធម្មតា បានតំរូវឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើការកែសំរួលឡើងវិញ នូវបញ្ជីថ្លៃលក់អគ្គិសនីឱ្យអគ្គីសនីកម្ពុជាដែលសំណើសុំគោលការណ៍កំណត់ថ្លៃថ្មីនេះ ត្រូវបានលើកយកមកពិភាក្សា នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃ សុក្រ សប្តាហ៍មុន ។

ប្រភពពត៌មានពីមន្ត្រីម្នាក់ ដែលបានចូលរួមប្រជុំដោយសុំមិនបញ្ចេញឈ្មោះ បាននិយាយប្រាប់ថាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដែលដឹកនាំដោយ ឯ.ឧ ឧបនាយករដ្ឋមន្ត្រី ស ខេង កាលពីថ្ងៃទី ១៦ កញ្ញា ២០០៥ បានសំរេចរួចហើយលើសំណើសុំគោលការណ៍កំណត់បញ្ជីថ្លៃអគ្គិសនីថ្មី ដែលមាន

តំលៃខ្ពស់ជាងមុនបន្តិច ដើម្បីដោះស្រាយវិបត្តិការផ្គត់ផ្គង់អគ្គិសនីក្នុងសភាពការណ៍បច្ចុប្បន្ន ដែលប្រេងឥន្ធនៈឡើងថ្លៃ ។

ប្រភពដែលនិយាយថា តារាងតំលៃថាមពលអគ្គិសនីសម្រាប់ផ្គត់ផ្គង់ឱ្យអតិថិជន អាចនឹងប្រកាសឱ្យដឹងនៅក្នុងសប្តាហ៍នេះ ប៉ុន្តែមិនទាន់ច្បាស់ថា ជម្រើសមួយណាដែលត្រូវយកមកអនុវត្តនោះទេ ពីព្រោះថា មានគោលការណ៍ពីរ ត្រូវក្រុមការងារធ្វើការពិភាក្សាគ្នាជ្រើសរើសយកអនុវត្ត គឺទី១ តម្លើងតំលៃបន្ថែមពីលើតំលៃចាស់ក្នុងមួយគីឡូវ៉ាត់ម៉ោង ។ ទី២ តំឡើងថ្លៃបន្ថែមគិតជាភាគរយទៅតាមកម្រិតនៃការប្រើប្រាស់ថាមពលច្រើន ឬតិច ។

ប្រភពដដែលបានបញ្ជាក់ថា គោលការណ៍តំឡើងថ្លៃថាមពលអគ្គិសនីនេះ នឹងត្រូវបានក្រុមការងារធ្វើការជួបប្រជុំពិភាក្សាគ្នាផ្តាច់ព្រ័ត នៅព្រឹកថ្ងៃ ច័ន្ទ នេះ ហើយនៅពេលរសៀល នឹងមានធ្វើសន្និសីទកុមូល ដែលបង្ហាញអំពីមូលហេតុតម្រូវឱ្យមានការឡើងថ្លៃថាមពលអគ្គិសនី ដែលនឹងមានចាក់ផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា ។

សេចក្តីប្រកាសពត៌មានរបស់ការិយាល័យអ្នកនាំពាក្យរាជរដ្ឋាភិបាល ចេញផ្សាយក្រោយពីការប្រជុំនេះ មានខ្លឹមសារថា ៖

ថ្ងៃទី១៦ កញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯ.ឧ ស ខេង នាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លង ៖

១-សំណើសុំគោលការណ៍កំណត់បញ្ជីថ្លៃលក់អគ្គិសនីអោយអគ្គិសនិកម្ពុជាជាថ្មី ដើម្បីដោះស្រាយវិបត្តិផ្គត់ផ្គង់អគ្គិសនីក្នុងសភាពការណ៍បច្ចុប្បន្ន ដែលប្រេងឥន្ធនៈឡើងថ្លៃបន្ថែមទៀត

២-បញ្ហាផ្សេងៗ៖ សំណើរសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិបញ្ញត្តិលើ "អនុសញ្ញា កុងស៊ុល រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម" ។

ក្រោយពីបានពិភាក្សា និងផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសំរេច ៖

*I- លើសំណើសុំគោលការណ៍កំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យអគ្គិសនីកម្ពុជាជាថ្មី*
*ដើម្បីដោះស្រាយវិបត្តិផ្គត់ផ្គង់អគ្គិសនីក្នុងសភាពការណ៍បច្ចុប្បន្ន*
*ដែលប្រេងឥន្ធនៈឡើងថ្លៃបន្ថែមទៀត*

គណៈរដ្ឋមន្ត្រីបាន និងកំពុងពិភាក្សាលើការតម្លើងថ្លៃអគ្គិសនី ដើម្បីឱ្យមានតុល្យភាពនឹងតម្លៃប្រេងឥន្ធនៈ និងជៀសវាងការប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ចំពោះលទ្ធផលនៃការពិភាក្សា និងជូនដំណឹងនៅពេលក្រោយ ។

*II - បញ្ហាផ្សេងៗ*

អង្គប្រជុំគណៈរដ្ឋមន្ត្រីបានឯកភាពបញ្ជូន "អនុសញ្ញា កុងស៊ុល រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម" ដែលបានចុះហត្ថលេខា នៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ។ អនុសញ្ញានេះ ត្រូវបានធ្វើឡើងដោយយកតាមលំនាំអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីទំនាក់ទំនងកុងស៊ុលឆ្នាំ១៩៦៣ ដែលរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តយល់ព្រម កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥ ។/

## រដ្ឋមន្ត្រីកិច្ចការនារីធ្វើសន្និសីទកាសែត
## បន្ទាប់ពីច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារត្រូវបានសភាអនុម័ត

*លោក សួស សិរិត AKP ភ្នំពេញ*

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលមាន ៨ជំពូក និង ៣៧មាត្រា ត្រូវបានសភាអនុម័តជាស្ថាពរ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥នេះ ។ ក្រោយពីបានសភាអនុម័តច្បាប់នេះរួចហើយ លោកជំទាវ អ៊ឹង គន្ធាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានធ្វើសន្និសីទសារព័ត៌មានផ្សព្វផ្សាយអំពីច្បាប់នេះ ដើម្បីឱ្យសារព័ត៌មានជួយផ្សព្វផ្សាយជ្រួតជ្រាបដល់ប្រជាពលរដ្ឋ ។

លោកជំទាវ បានបញ្ជាក់ថា សមាជិកសភា ៨៨រូប លើ ៨៨រូប បានលើកដៃអនុម័តជាផ្លូវការលើច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនេះ ។ ក្រោយពីច្បាប់នេះកើតឡើង លោកជំទាវមានជំនឿថានឹងត្រូវយកទៅអនុវត្តការការពារកុំឱ្យអំពើហិង្សាចេះតែកើតឡើងទៅលើក្រុមគ្រួសារទាំងឡាយ ដែលភាគច្រើនកើតចេញពីបុរស ។ កន្លងមកនៅប្រទេសកម្ពុជាអំពើហិង្សាកើតឡើងទៅលើស្ត្រី ២៣% ភាគច្រើនស្ត្រីដែលមានអាយុចាប់ពី ១៥ ទៅ ៤៩ឆ្នាំ ដែលជាជនរងគ្រោះ ។ អំពើហិង្សានោះទៀតសោត ច្រើនកើតចេញពីបុរសមានជាតិស្រវឹង ភាពអវិជ្ជា និងល្បែងស៊ីសង ។ល។ នៅក្នុងជំពូកទី១ នៃបទប្បញ្ញត្តិបានចែងថា គឺចង់ឱ្យមានគោលដៅមួយឱ្យក្រុមគ្រួសារមានការរស់នៅជួបជុំគ្នាជាជាងធ្វើឱ្យគ្រួសារមានការបែកបាក់ ។ ចំណុចទី២ ផ្តល់ជំនួយ និងការគាំទ្រប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ បើទោះបីពួកគេរស់នៅទីជនបទក៏ដោយ ។ ចំណុចទី៣ ច្បាប់នឹងត្រូវបង្កើតឱ្យមានឱកាសដល់ជនមុខសញ្ញាដែលធ្លាប់តែប្រើអំពើហិង្សានៅក្នុងគ្រួសារ ដើម្បីកែប្រែឥរិយាបថរបស់ខ្លួនឱ្យទៅជាមនុស្សស្លូតបូត ។ ចំណុចទី៤ ច្បាប់នេះក៏នឹងត្រូវពង្រឹងឱ្យមានរបៀបដោះស្រាយទំនាស់ដោយអហិង្សា និងសន្តិវិធីតាមប្រពៃណីព្រះពុទ្ធសាសនា ។

លោកជំទាវ បានបន្តទៀតថា យើងចង់ឱ្យមានច្បាប់នេះឡើង ដើម្បីប្រៀនប្រដៅ អប់រំមនុស្សប្រកបដោយព្រហ្មវិហារធម៌ ហើយប្រសិនបើបុគ្គលដែលធ្លាប់តែមួម៉ៅក្នុងគ្រួសារ ធ្វើបាបប្រពន្ធកូន ត្រូវតែ

កែប្រែខ្លួនឱ្យក្លាយទៅជាមនុស្សល្អតបូត ។ យើងចង់ឱ្យធ្វើបែបនេះ ដើម្បីស្របទៅតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។ ទោសទណ្ឌទាំងឡាយ យើងមិនចង់បង្កើតឱ្យមានទៅលើក្រុមគ្រួសារកើតមានអំពើហិង្សានោះទេ ប៉ុន្តែយើងចង់ឱ្យគេលះបង់នូវសកម្មភាព ដែលគេធ្លាប់ប្រព្រឹត្តខុសឆ្គងកន្លងមក ។ នៅក្នុងជំពូកទី៤ ច្បាប់នេះបានដាក់បញ្ញត្តិលើការធ្វើអន្តរាគមន៍ជាបន្ទាន់ដោយឱ្យអាជ្ញាធរមានសមត្ថកិច្ចអន្តរាគមន៍ ប្រសិនបើមានអំពើហិង្សាក្នុងគ្រួសារណាមួយ ។

នៅក្នុងជំពូកទី៧ បានចែងថា ជាការពិតច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនេះ មិនមានលក្ខណៈផ្ទុយពីច្បាប់ព្រហ្មទណ្ឌនោះដែរ ។ ចំណុចសំខាន់ៗ ដែលមាននៅក្នុងច្បាប់នេះបានចែងថា អំពើហិង្សាក្នុងគ្រួសារ គឺជាបទល្មើសមួយដែលត្រូវផ្តន្ទាទោស ។ ច្បាប់នេះអនុវត្តទៅលើប្តី និងប្រពន្ធកូនក្នុងបន្ទុក និងជនទាំងឡាយណាដែលរស់នៅក្រោមដំបូលផ្ទះ និងបន្ទុកក្រុមគ្រួសារតែមួយដែលទទួលរងនូវអំពើហិង្សា ។/

## ស្រុកសៀមរាប : ការិយាល័យច្រកចេញចូលតែមួយកំពុងប្រព្រឹត្តទៅយ៉ាងល្អ

*AKP សៀមរាប*

ស្របទៅនឹងនយោបាយកំណែទំរង់រដ្ឋបាលបែបវិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការបើកការិយាល័យច្រកចេញចូលតែមួយក្នុងស្រុកសៀមរាប ដែលបានចាប់ដំណើរការ កាលពីថ្ងៃទី៣១ មករា ២០០៥ កន្លងមក កំពុងតែប្រព្រឹត្តិទៅបានយ៉ាងល្អ ។

លោក សូ ឬាតុង អភិបាលស្រុកសៀមរាប បានឱ្យដឹងថា: រហូតមកដល់ពេលនេះមានប្រជាពលរដ្ឋកាន់តែច្រើនឡើងបានយល់ជ្រួតជ្រាបអំពី "ច្រកចេញចូលតែមួយ" នៅក្នុងការដាក់ពាក្យសុំលិខិតបញ្ជាក់សុំលិខិតអនុញ្ញាតប្រកបរបរអាជីវកម្មផ្សេងៗលើគ្រប់វិស័យ ដូចជាអាជីវកម្មទេសចរណ៍ ឧស្សាហកម្ម វប្បធម៌ ។ល។ ធ្វើប័ណ្ណកម្មសិទ្ធិ ផ្តល់ផ្លាកម៉ូតូ និងកិត្យានុកូលកម្ម ។ ហើយលិខិតក្នុងចំណោមទាំងនេះការធ្វើប័ណ្ណកម្មសិទ្ធ និងការផ្តល់ផ្លាកម៉ូតូបានចំនួន ១.៧១៩ លិខិតដែលជាចំនួនមួយខ្ពស់ជាងលិខិតស្តីពីវិស័យផ្សេងៗទៀត ។

លោក សូ ឬាតុង បានបញ្ជាក់ឱ្យដឹងថា: នៅក្នុងការិយាល័យច្រកចេញចូលតែមួយនេះ មានតំណាងស្ថាប័នរបស់ក្រសួងពាក់ព័ន្ធចំនួន ៩ កំពុងមានវត្តមាននៅទីនេះ ដើម្បីបញ្ចេញលិខិតស្នាមទាំងអស់ខាងលើនេះ ជូនប្រជាពលរដ្ឋ ។ មានដូចជា : តំណាងមកពីមន្ទីរសាធារណការ ដឹកជញ្ជូនខេត្ត មន្ទីរពាណិជ្ជកម្មខេត្ត មន្ទីរទេសចរណ៍ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ។

លោក តុប ជឿន មន្ត្រីផ្នែកឧស្សាហកម្ម នៃការិយាល័យច្រកចេញចូលតែមួយ បានឱ្យដឹងថា : លិខិតអនុញ្ញាតដែលចេញដោយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តដល់អាជីវករកន្លងមក មានជាអាទិ៍ ផ្នែកជួសជុលរថយន្ត ផ្សារដែក លាងរថយន្ត និងកាត់កញ្ចក់ជាដើម ។

លោកបន្តថា ផ្អែកតាមគោលការណ៍របស់ក្រសួងឧស្សាហកម្ម រាល់ការវិនិយោគទាំងឡាយណា ដែលមានទឹកប្រាក់ចាប់ពី ១០លាន ចុះ គឺអាជីវករត្រូវមកសុំលិខិតអនុញ្ញាតនៅការិយាល័យច្រកចេញចូល តែមួយនេះ ។

រាល់ការបង់ថ្លៃសេវាកម្មផ្សេងៗ ការិយាល័យច្រកចេញចូលតែមួយគត់របស់លោក បានកំណត់ តម្លៃនៅក្នុងតារាង ដោយដាក់តាំងបង្ហាញនៅលើក្តារខៀនជូនប្រជាពលរដ្ឋឱ្យបានដឹងមុន ។

លោក សូ ប្លាតុង បានអំពាវនាវដល់ប្រជាពលរដ្ឋទូទៅ ដែលមកសុំលិខិតអនុញ្ញាតផ្សេងៗ នៅកន្លែងលោក ធ្វើការប្តឹងទៅការិយាល័យប្រជាពលរដ្ឋនៅក្នុងករណីដែលមន្ត្រីបំរើការណាម្នាក់យកតំ លៃលើសពីតារាងកំណត់ ។

គួររំលឹកថា នៅថ្ងៃទី១១ មិថុនា ២០០៣ កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្តី សំរេចយកស្រុកសៀមរាបរបស់ខេត្តសៀមរាប និងស្រុកបាត់ដំបងរបស់ខេត្តបាត់ដំបង ដើម្បីអនុវត្តប្រព័ន្ធ រដ្ឋបាលបែបថ្មី តាមរយៈការបើកឱ្យមានការិយាល័យច្រកចេញចូលតែមួយ ។/

## បាត់ដំបងប្រារព្ធទិវាអនាម័យភពផែនដី ខែកញ្ញា ឆ្នាំ២០០៥

*លោក ឡេង ហុក AKP បាត់ដំបង*

កាលពីព្រឹកថ្ងៃទី១៥ កញ្ញា ឆ្នាំ២០០៥ នៅសាលមហោស្រពស្ទឹងសង្កែ ខេត្តបាត់ដំបង បាន ប្រារព្ធទិវាអនាម័យភពផែនដី ខែកញ្ញា ឆ្នាំ២០០៥ ក្រោមអធិបតីភាព ឯ.ឧ ខុង សំនួន រដ្ឋលេខាធិ ការក្រសួងបរិស្ថាន លោក អ៊ុក វង្ស អភិបាលរងខេត្តបាត់ដំបង លោក ជា រស់ មេបញ្ជាការរងយោធ ភូមិភាគទី៥ ព្រមទាំងប្រជាពលរដ្ឋ និងសិស្សានុសិស្សចូលរួមទាំងអស់ប្រមាណ ៧០០នាក់ ។

លោក សេង សារី អគ្គនាយកក្រុមហ៊ុនស៊ីនទ្រី (កម្ពុជា) ចំកាត់ មានប្រសាសន៍ឱ្យដឹងថា : មុននេះ បរិស្ថានធម្មជាតិ ជាប្រភពធនធានយ៉ាងសំខាន់ ក្នុងការគាំពារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ បច្ចុប្បន្ននេះ បរិស្ថានធម្មជាតិក៏នៅរក្សាតួនាទីរបស់ខ្លួនដដែល ដែលមានន័យថា គុណភាពជីវិតរបស់ប្រ ជាជន គឺចំណុះនឹងគុណភាពបរិស្ថាន ព្រោះស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន គឺវាចំណុះនឹងបរិមាណធន ធានធម្មជាតិ ដែលមានក្នុងបរិស្ថានធម្មជាតិ ដូច្នេះបរិស្ថាន គឺជាកត្តាកំណត់សំខាន់បំផុត ចំពោះគុណ ភាពសេដ្ឋកិច្ច និងគុណភាពសុខភាពរបស់ប្រជាជន ។

លោក អ៊ុក វង្ស មានប្រសាសន៍ក្នុងពិធីនោះថា: ខេត្តបាត់ដំបងមានភូមិសាស្ត្រធំទូលាយ សំបូរទៅដោយធនធានធម្មជាតិ ហើយដីមានជីជាតិគុណភាពល្អ អាចដាំដុះនូវដំណាំបានច្រើនប្រភេទ អាចរួមចំណែកទ្រទ្រង់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងជីវភាពប្រជាពលរដ្ឋយ៉ាងល្អប្រសើរ ។ លោកអភិបាលរងខេត្តថ្លែងបន្តថា : ក្រោយភ្លើងសង្គ្រាមរួសបន្លាយជាងពីរទសវត្សបានរលត់ទៅ កំណើនប្រជាពលរដ្ឋគួបផ្សំនឹងការអភិវឌ្ឍន៍លើគ្រប់វិស័យ មានភាពរីកចំរើនគួរឱ្យកត់សំគាល់នោះ បានធ្វើឱ្យបរិមាណសំណល់គ្រប់ប្រភេទមានការកើនឡើងជារៀងរាល់ថ្ងៃ ។ ទោះបីអាជ្ញាធរខេត្តបានខិតខំធ្វើការកែលំអរម្មណីយដ្ឋាន និងរៀបចំសួនលំហែថ្មីៗជាច្រើនសំរាប់លើកកំពស់សោភ័ណភាពបរិស្ថាន ទាំងនៅទីរួមខេត្ត និងក្នុងស្រុកមួយចំនួនដើម្បីបំរើការកំសាន្តដល់ប្រជាពលរដ្ឋ ព្រមទាំងភ្ញៀវទេសចរជាតិ អន្តរជាតិយ៉ាងណាក៏ដោយ ក៏ការគ្រប់គ្រង នឹងការទុកដាក់សំណល់សំរាមផ្សេងៗ នៅទីតាំងខ្លះធ្វើពុំទាន់បានល្អស្អាតត្រឹមត្រូវនៅឡើយ ដោយប្រជាពលរដ្ឋយើងខ្វះការយល់ដឹងស៊ីជំរៅ ជាហេតុនាំឱ្យការចូលរួមថែរក្សាអនាម័យ នៅមានកំរិតម្យ៉ាងទៀតសកម្មភាពនៃការអប់រំផ្សព្វផ្សាយ និងការអនុវត្តច្បាប់ការពារបរិស្ថានមិនទាន់បានធ្វើឱ្យជាប់ជាប្រចាំនោះ ។

ឯកឧត្តម ខុង សំនួន រដ្ឋលេខាធិការក្រសួងបរិស្ថាន មានប្រសាសន៍ក្នុងពិធីនោះថា : ការប្រារព្ធទិវាអនាម័យភពផែនដី ខែកញ្ញា នេះ គឺជាការចូលរួមចំណែកដ៏ថ្លៃថ្លារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេច ហ៊ុន សែន ជាប្រមុខ ក្នុងការអនុវត្តតាមសេចក្តីអំពាវនាវរបស់បណ្តាញភ្នាក់ងារអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិប្រចាំនៅប្រទេសអូស្ត្រាលី ដែលស្នើឱ្យគ្រប់បុគ្គលិក និងឱ្យគ្រប់សហគមន៍ប្រជាជាតិទាំងអស់លើភពផែនដីធ្វើការសំអាតបរិស្ថានរស់នៅរបស់ពួកគេឱ្យបានស្អាត ប្រកបដោយផាសុខភាពហើយសកម្មភាពនេះបានផ្តួចផ្តើមឡើងតាំងពីឆ្នាំ ១៩៩៣ មកម្ល៉េះ ។

លោក ខុង សំនួន ថ្លែងថា ដំបូងបង្អស់ គឺអនុវត្តត្រឹមតែក្របខ័ណ្ឌ ធ្វើអនាម័យបរិស្ថាននៅប្រទេសអូស្ត្រាលីតែប៉ុណ្ណោះ ហើយសកម្មភាពនេះបានរីករាលដាលក្លាយទៅជាយុទ្ធនាការសំអាតបរិស្ថានមួយយ៉ាងទូលំទូលាយ ដែលមានមនុស្ស ៣៥លាននាក់ មកពីជាង ១២០ប្រទេស លើសកលលោក ចូលរួម ។

ឯកឧត្តម ខុង សំនួន ឱ្យដឹងទៀតថា : ការកើតមានយុទ្ធនាការទិវាអនាម័យភពផែនដី ខែកញ្ញា រៀងរាល់ឆ្នាំនេះ គឺផ្តើមចេញពីសកម្មភាពមនុស្សយើងបានបំពុលបរិស្ថាន នាំឱ្យបរិស្ថានលើដី ក្នុងដី ក្នុងទឹក និងក្នុងបរិយាកាសមានសភាពកខ្វក់ ។ ក្នុងនោះដែរ ចលនាពិភពលោក គឺមិនចង់ឱ្យមានសំរាម និងសារធាតុពុល និងតម្រូវឱ្យបំបាត់ឡដុតសំរាម ដែលធ្វើឱ្យមានការបំពុលដល់សុខភាពសារធារណៈទៀតផង ។

តាមការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ការដុតសំរាម បង្កើតឱ្យមានជម្ងឺមហារីក ការបំភាយសារធាតុពុល DIOXIN និង HEAVY metals ធ្វើឱ្យខូចប្រព័ន្ធការពារខ្លួនមនុស្ស និងបរិស្ថានទៀតផង ។/

## មជ្ឈមណ្ឌលពត៌មានទេសចរណ៍សហគមន៍
## ថ្នាក់ឃុំ បានបង្កើតជាលើកដំបូង នៅឃុំចំបក់ ស្រុកភ្នំស្រួច

*លោក លីម សាន្ត AKP កំពង់ស្ពឺ*

កាលពីដើមខែកញ្ញា កន្លងទៅនេះ មជ្ឈមណ្ឌលពត៌មានទេសចរណ៍ថ្នាក់សហគមន៍ ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ត្រូវបានសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការដោយអង្គការម្លប់បៃតង ដើម្បីទុកជាផលប្រយោជន៍របស់ប្រជាពលរដ្ឋឃុំចំបក់ទាំងមូលពីពេលនេះតទៅ ។

លោក វ៉ា មឿន នាយកប្រតិបត្តិនៃអង្គការម្លប់បៃតង បានអោយដឹងថា: មជ្ឈមណ្ឌលពត៌មានបានសង់អគារមួយខ្នង មានទំហំ ៨ម៉ែត្រ គុណនឹង ១២ម៉ែត្រ ចំណាយថវិកាអស់ជាង ២ម៉ឺនដុល្លារ ដែលរួមទាំងការបំពាក់សំភារៈប្រើប្រាស់ផងនោះ ត្រូវបានចាត់ទុកជាមជ្ឈមណ្ឌលពត៌មានទេសចរណ៍ ថ្នាក់សហគមន៍លើកតំបូង ដែលបានកសាងឡើងនៅប្រទេសកម្ពុជា ។

លោក វ៉ា មឿន បានបន្តទៀតថា : សមជ្ឈមណ្ឌលនេះ មានតួនាទីសំរាប់ផ្សព្វផ្សាយពត៌មានដែលទាក់ទងទៅនឹងធនធានធម្មជាតិ និងវប្បធម៌ប្រពៃណីដ៏មានតំលៃនៅតំបន់នោះ ដល់សាធារណៈជន និងភ្ញៀវទេសចរ ។ មជ្ឈមណ្ឌលក៏នឹងត្រូវប្រើប្រាស់ជាកន្លែងធ្វើការរបស់គណៈកម្មការទេសចរណ៍ធម្មជាតិចំបក់ កន្លែងរៀនសូត្រ ប្រាស្រ័យទាក់ទង និងជាទីកន្លែងផ្សព្វផ្សាយពត៌មានផ្សេងៗផងដែរ ។

លោក វ៉ា មឿន បានបន្ថែមទៀតថា : មជ្ឈមណ្ឌលនេះបង្កើតឡើងក្នុងគោលបំណងពិសេស គ្រប់គ្រងលើសេវាទេសចរណ៍ធម្មជាតិតំបន់ទឹកធ្លាក់ជើងភ្នំគិរីរម្យ ។ ក្រៅពីនេះ មជ្ឈមណ្ឌលសហគមន៍ចំបក់មានភារកិច្ចអភិរក្សតំបន់ព្រៃធម្មជាតិ ដែលត្រូវបានធ្វើដែនកំណត់ជាមួយក្រសួងបរិស្ថានទៀតផង ។ សារៈសំខាន់របស់សហគមន៍មិនត្រឹមទាញយកផលពីព្រៃធម្មជាតិ សំរាប់បំរើប្រជាសហគមន៍ទេ ថែមទាំងជួយថែរក្សាធនធានធម្មជាតិឱ្យមាននិរន្តរភាពទៀតផង ។

គួរលើកថា : សហគមន៍ទេសចរណ៍ថ្នាក់ឃុំចំបក់នេះ បានបើកដំណើរការជាផ្លូវការចាប់តាំងពីថ្ងៃទី៤ មករា ឆ្នាំ២០០៣ មកម្ល៉េះ ដោយមានការចូលរួមពីប្រជាពលរដ្ឋចំនួន ៩ភូមិ នៃឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

សហគមន៍ទេសចរណ៍ធម្មជាតិចំបក់នេះ បានបង្កើតជាគណៈកម្មការដែលមានសមាជិក១៣រូប ជាតំណាងនៃភូមិនីមួយៗ និងតំណាងស្ត្រី ៤រូប ។ គណៈកម្មការនេះ បានបង្កើតជាផ្នែកផ្សេងៗ ដូចជា ផ្នែកល្បាត ផ្នែកនាំភ្ញៀវ ផ្នែកតន្ត្រី និងរបាំ ផ្នែកគណនេយ្យ ផ្នែកចំណត និងផ្នែកលក់ដូរផងដែរ ។/

## ខេត្តបន្ទាយមានជ័យ : តាំងពិព័រណ៍មិត្តភាព កម្ពុជា-ថៃ ភូមិមួយផលិតផលមួយ

*លោក ឈុន សារ៉ាត AKP បន្ទាយមានជ័យ*

មុខទំនិញជាច្រើនបានដាក់តាំង និងលក់នៅក្នុងស្តង់ចំនួន ៦៩កន្លែង នៅក្នុងទីតាំងពិព័រណ៍មិត្តភាព ភូមិមួយផលិតផលមួយ កម្ពុជា-ថៃ ដែលបានរៀបចំឡើងនៅក្នុងវេទិការខេត្តបន្ទាយមានជ័យ ដែលមានរយៈពេល ២ថ្ងៃ ថ្ងៃទី១៥ ទៅ ១៦ កញ្ញា ឆ្នាំ២០០៥នេះ ។

ការតាំងពិព័រណ៍មិត្តភាព កម្ពុជា-ថៃ ភូមិមួយផលិតផលមួយនេះ ត្រូវបានធ្វើឡើងរវាងភាគីកម្ពុជា ដែលមានខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប រួមជាមួយនឹងភាគីថៃ ដែលមានខេត្ត ក្រុមខេត្តសម្ព័ន្ធមិត្ត មាន ខេត្តស្រះកែវ ខេត្តប្រាជិនបុរី ខេត្តឆាក់ឈាងសៅ ខេត្តសាមុតប្រាកាណ និង ណះខនង៉ាយុត ។

នៅក្នុងការតាំងពិព័រណ៍នេះ ភាគីកម្ពុជា រួមមាន ២២ស្តង់ ដោយមានការដាក់តាំងលក់នូវផលិតផលដែលជាស្នាដៃរបស់សិប្បករ និងកសិករខ្មែរ រួមមាន ចម្លាក់ ហូល ផាមួង សិប្បកម្មដែលធ្វើដោយដៃ និងឥវ៉ាន់ផ្សេងៗជាច្រើនមុខទៀត ។

រីឯក្រុមខាងភាគីថៃ បាននាំយកមកនូវមុខទំនិញ ដូចជា ម្ហូបអាហារ គ្រឿងណាត់ សម្ភារៈប្រើប្រាស់ វត្ថុអនុស្សាវរីយ៍ និងរុក្ខជាតិឱសថ មកដាក់លក់ រួមមានចំនួន ៤៧ស្តង់ ។

លោក សុខ សារ៉េត អភិបាលរងខេត្តបន្ទាយមានជ័យ បានថ្លែងថា : ជាលើកទី៦ហើយដែលការតាំងពិព័រណ៍របៀបនេះបានស្នើឡើង ដើម្បីតាំងបង្ហាញនូវមុខទំនិញមួយចំនួននៅបណ្តាខេត្តខាងលើនៅប្រទេសទាំងពីរផលិតបាន ដែលភាគច្រើនចេញពីស្នាដៃរបស់កសិករ និងសិប្បករ.. ។

លោក សុខ សារ៉េត បន្តទៀតថា យើងរួមគ្នាចាត់វិធីពិព័រណ៍នៅពេលនេះ គឺក្នុងគោលបំណងដើម្បីកសាងនូវកិច្ចទំនាក់ទំនងល្អនៃការពង្រឹងទីផ្សារព្រំដែន និងកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗទៀតឱ្យកាន់តែប្រសើរឡើង ហើយក៏ដើម្បីជួយផ្តល់ការងារមុខរបរជូនប្រជាជននៅតំបន់ព្រំដែន និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រជូនគាត់ និងឱ្យប្រជាពលរដ្ឋបន្តច្នៃប្រឌិតផលិតមុខទំនិញរបស់ខ្លួនឱ្យមានសន្ទុះកើនឡើង ដែលឈានទៅដល់ការរៀបចំ ភូមិមួយផលិតផលមួយ ប្រកបដោយជោគជ័យ ។

លោកអភិបាលរងខេត្ត ថ្លែងបន្តថា ពិធីតាំងពិព័រណ៌ យើងពុំបានគិតអំពីការខាត និងចំណេញក្នុងកិច្ចការរកស៊ីលក់ដូរនេះទេ តែយើងនឹងក្រេបយកនូវបទពិសោធន៍ពីការរៀបចំទំនិញ ដូចជាបរិមាណ គុណភាព សោភ័ណភាព ការវេចខ្ចប់ តម្លៃ ។ល។ ឱ្យបានសមស្រប ដើម្បីទាក់ទាញអ្នកទិញ និងចរាចរនៅទីផ្សារបានល្អ ទាំងនៅក្នុងតំបន់ព្រំដែនជាប់គ្នា ទាំងនៅក្នុងប្រទេស ទាំងនៅលើបណ្តាប្រទេសក្នុងតំបន់លើទីផ្សារអន្តរជាតិទៀតផង ។

លោក ស៊ូ រីកវ៉ាតឆ: ឡូថាយ៉ាគូន អភិបាលរងខេត្តស្រះកែវ នៃប្រទេសថៃ បានគូសបញ្ជាក់ថា ការតាំងពិព័រណ៌ ភូមិមួយផលិតផលមួយ របស់ភាគីកម្ពុជា និងក្រុមខេត្តសម្ព័ន្ធមិត្តនៃប្រទេសថៃ គឺមានគោលបំណង ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងថៃ-កម្ពុជា ក៏ដូចជាផ្នែកពាណិជ្ជកម្មវិនិយោគទេសចរណ៍ ឧស្សាហកម្ម សេវាកម្មផ្សេងៗ រួមទាំងការជួយគាំទ្រលើកស្ទួយនូវផលិតផល ដែលបានកើតមកពីគំនិតច្នៃប្រឌិតរបស់ប្រជាជននៅតាមមូលដ្ឋាននៃភាគីទាំងពីរ កម្ពុជា-ថៃ ផងដែរ ។/

## ក្រុងព្រះសីហនុប្រារព្ធទិវាអបអរសាទរសំអាតឆ្នេរ

*លោក ងួ សុមុនី AKP ក្រុងព្រះសីហនុ*

កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ នៅឆ្នេរអូរឈើទាល ក្រុងព្រះសីហនុ បានប្រារព្ធទិវាអបអរសាទរសំអាតឆ្នេរអន្តរជាតិ ថ្ងៃទី៣ កញ្ញា ឆ្នាំ២០០៩ ដែលមានការចូលរួមពីអាជ្ញាធរក្រុងគ្រប់ស្ថាប័ន អង្គភាពរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ និងអាជីវករលក់ដូរនៅតាមតំបន់ឆ្នេរ ។

ឯកឧត្តម ប្រាក់ ស៊ីហារ៉ា អភិបាលរងទី២ក្រុង និងជាប្រធានគំរោងគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរបែបសមាហរណកម្ម បានមានប្រសាសន៍ថា ការចូលរួមសំអាតបរិស្ថានតំបន់ឆ្នេរអូរឈើទាល ក្នុងន័យចូលរួមអបអរសាទរទិវាសំអាតឆ្នេរអន្តរជាតិ ៣ កញ្ញា ឆ្នាំ២០០៩ ដែលជាសក្ខីភាពឆ្លុះបញ្ចាំងអំពីស្មារតីការពារ ថែរក្សាបរិស្ថាននៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយឡែក បរិស្ថាននៅតំបន់ឆ្នេរក្រុងព្រះសីហនុឱ្យមានសោភ័ណភាពស្រស់ត្រកាល និងមានពណ៌បៃតងជានិច្ច តម្រូវឱ្យគ្រប់ស្ថាប័ន អង្គភាពរដ្ឋ ប្រជាពលរដ្ឋទាំងអស់យកចិត្តទុកដាក់បញ្ហាកាកសំណល់រឹង រាវ ដែលជាបញ្ហាអាទិភាពមួយដែលកើតមានស្ទើរគ្រប់ទីកន្លែង បង្កឱ្យមានការបំពុលបរិស្ថាន ជាហេតុឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ជាពិសេសភ្ញៀវទេសចរ និងបាត់បង់សោភ័ណភាពទីក្រុង បង្កឱ្យមានការចម្លងមេរោគផ្សេងៗដល់ប្រជាពលរដ្ឋ ដែលជះឥទ្ធិពលដល់សង្គម និងសេដ្ឋកិច្ចជាតិ ។ ដូច្នេះការចូលរួមសំអាតឆ្នេរអូរឈើទាលនាពេលនេះ វាជាសក្ខីភាពមួយបង្ហាញឱ្យឃើញអំពីការខិតខំប្រឹងប្រែងរបស់អាជ្ញាធរក្រុង ក្នុងការចូលរួមផ្សព្វផ្សាយអប់រំជាសាធារណៈឱ្យយើងទាំងអស់គ្នាចូលរួមគ្រប់គ្រងកាកសំណល់រឹង រាវឱ្យបានល្អ ការពារបរិស្ថាន ដែលនាំមកនូវអនាម័យ

សោភ័ណភាព រក្សាបានធនធានធម្មជាតិ ជីវចំរុះ និងបែបបណ្តុះធម្មជាតិ ដើម្បីបំរើឱ្យវិស័យទេសចរណ៍ធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រ ក្រុងព្រះសីហនុ ។

គួរបញ្ជាក់ថា កាលពីខែមិថុនា ឆ្នាំ២០០៩ កន្លងមកនេះ អាជ្ញាធរក្រុងសហការជាមួយស្ថាប័នអង្គភាពរដ្ឋ ប្រជាពលរដ្ឋទាំងអស់បានប្រារព្ធទិវាបរិស្ថានពិភពលោក និងទិវាភពផែនដី សំអាតឆ្នេរនៅតំបន់អូរឈើទាលនេះផងដែរ ។/